01044507

លេខ / N°: A66

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
(Date of receipt/date de reception): 08 / 12 / 2014
(Time/Heure): 10:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No:003/07-09-2009-ECCC-OCIJ**

# ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង
# Summons to Initial Appearance
# Convocation à Interrogatoire de Première Comparution

ខ្ញុំ **Mark B. Harmon** សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ**វិធាន ២១, ៤១, ៤៥, ៥៥, ៥៧ និង៧២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង")។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤("ដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរបន្ថែម"[2]។

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩

[2]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥00, ៥0១, ៥0៣, ៥0៥, ៥0៦, ៥0៧ និង ៥0៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះបញ្ជីនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២0១៣ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាម ២0១៣។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះបញ្ជីនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២0១៤។

**អាស្រ័យហេតុនេះ** កោះហៅ ៖

**មាស មុត** ហៅ អាចារ្យ នេន

ភេទ៖ ប្រុស

ថ្ងៃខែឆ្នាំកំណើត៖ ១៩៣៨

ស្រុកកំណើត៖ ភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត

សញ្ជាតិ៖ ខ្មែរ

ទីលំនៅបច្ចុប្បន្ន៖ ភូមិតាសាញ ជើង ស្រុកសំឡូត ខេត្តបាត់ដំបង

ឈ្មោះប្រពន្ធ៖ ខុំ (Khom) (ស្លាប់) និង ខា (Kha)

ឈ្មោះកូន៖ ភាព និងវុធ

ជាប់ឈ្មោះជាជនសង្ស័យម្នាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

មានរូបថតដូចបានភ្ជាប់ជាមួយ។

**ឲ្យមកបង្ហាញខ្លួននៅចំពោះមុខខ្ញុំ នៅ អ.វ.ត.ក មានទីតាំងនៅផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ**

**នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២0១៤ ម៉ោង១ រសៀល**

**សម្រាប់ការបង្ហាញខ្លួនលើកដំបូង**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ៧១ ទូរសព្ទលេខ +៨៥៥(0)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៩៨៤១។

ប្រសិនបើ មាស មុត មិនមកបង្ហាញខ្លួនតាមកាលបរិច្ឆេទដូចបានបញ្ជាក់ខាងលើទេ វិធានការបន្ថែមទៀតដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នឹងត្រូវយកមកពិចារណា។

មាស មុត ត្រូវបានដំណឹងអំពី៖

- សិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់គាត់ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ១១, ២១ និង២២ និងបទបញ្ជារដ្ឋបាលដែលចូលជាធរមាន។
- សិទ្ធិមានវត្តមានរបស់មេធាវីនៅក្នុងអំឡុងពេលនៃការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៥៧
- សិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ អនុលោមតាមវិធានផ្ទៃក្នុង ៥៧
- សិទ្ធិផ្តល់ចម្លើយដោយមានកំណត់ហេតុ ដោយមានវត្តមានរបស់មេធាវី នៅក្នុងអំឡុងពេលនៃការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៥៧ និង
- សិទ្ធិពិគ្រោះជាមួយមេធាវី មុនពេលគាត់ត្រូវបានសួរចម្លើយនៅក្នុងដំណាក់កាលណាមួយនៃការស៊ើបអង្កេត។

សហមេធាវីរបស់មាស មុត គឺលោក អាង ឧត្តម និងលោក Michael G. Karnavas ក៏នឹងត្រូវកោះហៅឲ្យចូលរួមការបង្ហាញខ្លួនលើកដំបូងនេះផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ចៅក្រម Mark B. Harmon

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

International Co- Investigating Judge

Co-juge d'instruction International

01044510

០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស **លេខ៖** A66

# លិខិតទទួលស្គាល់ការប្រគល់ដីកាកោះ

ខ្ញុំ Thomas Kuehnel អ្នកស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រគល់ដីកាកោះនេះជូន មាស មុត មុត នៅថ្ងៃទី..28.......... ខែ..Nov......... ឆ្នាំ ២០១៤។

ខ្ញុំបានជូនដំណឹង មាស មុត ថា គាត់ត្រូវតែប្រគល់ដីកាកោះនេះជូនក្រឡាបញ្ជី នៅពេលដែលគាត់មកបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**អ្នកទទួល**

មាស មុត

*ហត្ថលេខា ឬស្នាមមេដៃ*

Refused to sign

**អ្នកប្រគល់**

Thomas Kuehnel

*ហត្ថលេខា*